# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

### ក្នុងនាមប្រជារាស្ត្រខ្មែរ
### សាលាដំបូងខេត្តកណ្ដាល

**សាលាដំបូងខេត្តកណ្ដាល**

**សំណុំរឿងរដ្ឋប្បវេណី**
លេខ: ៧០៥
ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៩
**សាលក្រមរដ្ឋប្បវេណី**
លេខ: ៣៨ "ឃ"
ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នាថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២០ ដោយមានសមាសភាពដូចតទៅ៖

**ចៅក្រមជំនុំជម្រះ**

លោកស្រី [redacted] ចៅក្រមសាលាដំបូងខេត្តកណ្ដាល

**ក្រឡាបញ្ជី**

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្ដាល

-រវាងដើមចោទឈ្មោះ [redacted] សឿន ភេទប្រុស អាយុ ៤៧ឆ្នាំ ជនជាតិខ្មែរ មានអាសយដ្ឋាននៅផ្ទះ [redacted]។

ដោយមានមេធាវី [redacted] អត្តលេខ ៧៨២ ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ មានការិយាល័យក្រុមមេធាវី [redacted]។

-និងចុងចម្លើយឈ្មោះ [redacted] ពីន ភេទប្រុស អាយុ ៣៧ឆ្នាំ ជនជាតិខ្មែរ មានអាសយដ្ឋាននៅភូមិ [redacted]។

ដោយមានមេធាវី [redacted] អត្តលេខ ៩២៥ និងមេធាវី [redacted] អត្តលេខ ២០០៤T ជាមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ មានការិយាល័យនៅ [redacted] អគារលេខ [redacted]។

<u>ដែលមានកម្មវត្ថុ</u> សុំរំលាយកិច្ចសន្យា ។

-បានឃើញ ពាក្យបណ្តឹង ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] សឿន ។
-បានឃើញ ពាក្យសុំកែប្រែកម្មវត្ថុបណ្តឹង ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ របស់មេធាវី [redacted]
-បានឃើញ ពាក្យបណ្តឹងតប ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] ពីន។
-បានឃើញ កិច្ចសន្យាកក់ប្រាក់ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៩។
-បានឃើញ លិខិតជូនដំណឹង ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ របស់មេធាវី [redacted]។
-បានឃើញ លិខិតជូនដំណឹង (ដាច់ប្រាក់កក់ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៩) ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៩ របស់មេធាវី [redacted]។
-បានឃើញ លិខិតជូនដំណឹង (ពីការបញ្ចប់កិច្ចសន្យា កក់ប្រាក់ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៩) ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៩ របស់មេធាវី [redacted]។
-បានឃើញ ឯកសារចម្លើយ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] ពីន។



Scanned with CamScanner

-បានឃើញ ឯកសារត្រៀម ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២០ របស់មេធាវី [redacted] និងមេធាវី [redacted]។

-បានឃើញ លិខិតរបស់ឈ្មោះ [redacted] ពីន ផ្ញើជូន ឈ្មោះ [redacted] សឿន ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការអនុវត្តករណីកិច្ចបង់ប្រាក់ នាថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩។

-បានឃើញ ពាក្យស្នើសុំឱ្យពិនិត្យភស្តុតាង ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩ របស់មេធាវី [redacted]។

-បានឃើញ អាជ្ញាប័ណ្ណ សម្រាប់ធ្វើសេវាកម្មអគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជា លេខ ២០៩ L ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៤ របស់អាជ្ញាធរអគ្គិសនីកម្ពុជា។

-បានឃើញ សេចក្តីថ្លែងការណ៍ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២០ របស់មេធាវី [redacted] និងមេធាវី [redacted]។

## អង្គហេតុ និងចំណុចវិវាទ

**១) ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ៖**

១.១-សុំរំលាយកិច្ចសន្យា ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៩ រវាងឈ្មោះ [redacted] សឿន និងឈ្មោះ [redacted] ពីន។

១.២-ប្រាក់កក់ចំនួន ៥០០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក ក្នុងកិច្ចសន្យាកក់ប្រាក់ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៩ រវាងឈ្មោះ [redacted] សឿន និងឈ្មោះ [redacted] ពីន ទុកជាកម្មសិទ្ធិរបស់ឈ្មោះ [redacted] សឿន។

១.៣-សុំទាមទារសំណងជម្ងឺចិត្តជាប្រាក់ ចំនួន ២០លានរៀល ពីចុងចម្លើយ។

១.៤-សុំអនុវត្តបណ្តោះអាសន្ន លើចំណុចទី១ និងទី២។

១.៥-ប្រាក់ពន្ធ និងប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

**២) ខ្លឹមសារនៃសាលក្រមដែលចុងចម្លើយ (ដើមបណ្តឹងតប) ទាមទារ៖**

២.១. បង្គាប់ឱ្យចុងបណ្តឹងតបឈ្មោះ [redacted] សឿន ផ្ទេរភាគហ៊ុន ចំនួន ៥៤% នៅក្នុងសហគ្រាសអគ្គិសនី សុខ ពីន 209L មកឱ្យដើមបណ្តឹងតប ឈ្មោះ [redacted] ពីន តាមកិច្ចសន្យាកក់ប្រាក់ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៩ រវាងអ្នកលក់ឈ្មោះ [redacted] សឿន និងអ្នកទិញឈ្មោះ [redacted] ពីន។

២.២.បង្គាប់ឱ្យចុងបណ្តឹងតបឈ្មោះ [redacted] សឿន សងសំណងនូវការខូចខាតសរុបចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក មកឱ្យដើមបណ្តឹងតបឈ្មោះ [redacted] ពីន។

២.៣. សុំឱ្យប្រកាសអនុវត្តជាបណ្តោះអាសន្នត្រង់ចំណុចទី១ ខាងលើ។

២.៤.បង្គាប់ឱ្យចុងចម្លើយជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្តី។

៣) <u>ការពន្យល់ត្រួសៗអំពីរឿងក្តី៖</u>

កាលពីថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៩ ឈ្មោះ [redacted] សឿន បានដាក់ពាក្យបណ្តឹងលើឈ្មោះ [redacted] ពីន រៀបចំឯកសារ ទិញលក់ភាគហ៊ុន និងព្រមព្រៀងផ្ទេរភាគហ៊ុន ៥៤% នៃអគ្គិសនី [redacted] ពីន (២០៩អ) ដោយលក់ក្នុងតម្លៃ ៤៥៩០០០$ (សែសិបប្រាំម៉ឺនប្រាំបួនពាន់ ដុល្លារអាមេរិក) ដោយឈ្មោះ [redacted] ពីន កក់ប្រាក់ចំនួន ៥០០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក ឱ្យឈ្មោះ [redacted] សឿន ប្រាក់នៅសល់ គឺចំនួន ៤០៩០០០$ (សែសិបម៉ឺនប្រាំបួនពាន់ ដុល្លារអាមេរិក) ទៀតបង់នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ជាកំហិត។ ស្រាប់តែនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ មានឯកសារពីមេធាវី មកប្រគល់ប្រាក់ឱ្យឈ្មោះ [redacted] សឿន តែចំនួន ២៨៩០០០$ (ម្ភៃប្រាំបីម៉ឺនប្រាំបួនពាន់ ដុល្លារអាមេរិក) តែប៉ុណ្ណោះ ដោយមិនឱ្យប្រាក់ឈ្មោះ [redacted] សឿន គ្រប់ចំនួនទេ។ សកម្មភាពនេះ ក្នុងនាមឈ្មោះ [redacted] សឿន ជាអ្នកលក់ភាគហ៊ុន មិនសុខចិត្ត ឈ្មោះ [redacted] សឿន ក៏បានប្រគល់សិទ្ធិជូនមេធាវីដើម្បីជូនដំណឹង ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៩ សុំឱ្យឈ្មោះ [redacted] ពីន បង់ប្រាក់ឱ្យគ្រប់ចំនួន គឺ៤០៩០០០$ (សែសិបម៉ឺនប្រាំបួនពាន់ ដុល្លារអាមេរិក) តែឈ្មោះ [redacted] ពីន មិនព្រមបង់ឱ្យគ្រប់ទេ គឺនៅតែអះអាងលើចំនួនដដែល ហើយបង្ខំឈ្មោះ [redacted] សឿន ឱ្យទទួលប្រាក់នោះដដែល។ ក្រោយមក ឈ្មោះ [redacted] សឿន ក៏បានជូន

ដំណឹងតាមរយៈឯកសារមេធាវី ពីការដាច់ប្រាក់កក់ និងបញ្ចប់កិច្ចព្រមព្រៀងលក់ទិញ ផ្ទេរភាគហ៊ុន ៥៤% នៃអគ្គិសនីសុខ ពីន (២០៩អ) ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៩ រវាងឈ្មោះ [redacted] សឿន និងឈ្មោះ [redacted] ពីន ដោយឈ្មោះ [redacted] សឿន ឈប់លក់វិញ ដោយមូលហេតុកំហុសធ្ងន់ធ្ងរ មិនអនុវត្តកាតព្វកិច្ចក្នុងការបង់ប្រាក់ ដោយសុំរំលាយកិច្ចសន្យា ប្រាក់កក់ វិញ។

៤) <u>ការអះអាងរបស់ភាគី៖</u>

-សេចក្តីថ្លែងការណ៍របស់មេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ៖ ខ្លួនសុំរក្សាពាក្យបណ្តឹង ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៩ និងសុំកែតម្រូវ ដូចក្នុងពាក្យកែតម្រូវ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩។ មូលហេតុ កូនក្តីខ្លួន បានចុះកិច្ចសន្យាទិញលក់ភាគហ៊ុន ៥៤% នៃអគ្គិសនី ២០៩អ ក្នុងតម្លៃ ៤៥៩០០០ (សែសិបប្រាំម៉ឺនប្រាំបួនពាន់) ដុល្លារអាមេរិក ដោយកក់ប្រាក់ចំនួន ៥០០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក និងកំណត់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ដើម្បីបង់ប្រាក់បង្គ្រប់។ មកដល់កំណត់ ចុងចម្លើយមិនបានយកលុយមកបង់ទេ ដោយបានជូនដំណឹងតាមរយៈមេធាវីថា ត្រូវបង់តែ ២៨៩០០០ (ម្ភៃប្រាំបីម៉ឺនប្រាំបួនពាន់) ដុល្លារអាមេរិក ទេ ហេតុនេះ កូនក្តីខ្លួន ក៏បដិសេធមិនទទួលយកប្រាក់នេះ ឬព័ត៌មាននេះទេ ហើយបានជូនដំណឹងត្រឡប់ទៅវិញ នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៩ កូនក្តីខ្លួនបានជូនដំណឹងទៅចុងចម្លើយ ឱ្យបង់លុយ ៤០៩០០០ (សែសិបម៉ឺនប្រាំបួនពាន់) ដុល្លារអាមេរិក ទើបកូនក្តីខ្លួនទទួលយក ប៉ុន្តែចុងចម្លើយមិនព្រម និងជូនព័ត៌មានថា ខ្លួននៅតែបង់ ២៨៩០០០ (ម្ភៃប្រាំបីម៉ឺនប្រាំបួនពាន់) ដុល្លារអាមេរិក ដដែល។ ក្រោយពីផុតរយៈពេល នៃការកំណត់ កូនក្តីខ្លួនបានជូនដំណឹងជាលាយលក្ខណ៍អក្សរ អំពីការបញ្ចប់កិច្ចព្រមព្រៀងទិញលក់ ៥៤% នៃអគ្គិសនី [redacted] ពីន និងសុំដាច់ប្រាក់កក់ចំនួន ៥០០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក នោះ។ ចំណែកឯបច្ចុប្បន្ន ភាគហ៊ុន ៥៤% និងប្រតិបត្តិការធានា គឺកូនក្តីខ្លួន កាន់កាប់ជាធម្មតា។ ចំពោះភាគហ៊ុនរបស់ចុងចម្លើយ ៣៣% រក្សាដដែល និងទទួលបានភាគហ៊ុនជាប្រចាំខែធម្មតា តាមរយៈការដកក្នុងថវិកាដែលអតិថិជនបានបង់។ ទាក់ទងនឹងមូលហេតុ សុំរំលាយកិច្ចសន្យាទិញភាគហ៊ុននេះ ដោយសារតែភាគីអ្នកទិញ មិនអនុវត្តកាតព្វកិច្ចនៃការបង់ប្រាក់ និងកូនក្តីខ្លួនបានជូនដំណឹងពីការបញ្ចប់កិច្ចសន្យា និងជូនដំណឹងពីការដាច់ប្រាក់កក់រួចរាល់ហើយ និងចំពោះសកម្មភាពនៃការគ្រប់គ្រងប្រតិបត្តិការនេះ គឺនៅធម្មតា។ ដូច្នេះ កូនក្តីខ្លួន សុំរំលាយកិច្ចសន្យា និងដាច់ប្រាក់កក់ទុកជាកម្មសិទ្ធិរបស់កូនក្តីខ្លួន។

-សេចក្តីថ្លែងការណ៍របស់មេធាវី[redacted]ជាមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ ៖ នៅពេលនីតិវិធីត្រៀមនេះ ខ្លួនសុំច្រានចោលការទាមទារគ្រប់ចំណុចទាំងអស់ក្នុងពាក្យបណ្តឹង ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៩ និងពាក្យសុំកែតម្រូវពាក្យបណ្តឹង ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩។ អំពីមូលហេតុនៃការសុំច្រានចោល៖ ដើមចោទ និងចុងចម្លើយ ពិតជាបានធ្វើសកម្មភាពអគ្គិសនីនៅព្រែកអំពិល ពិតប្រាកដមែន ដែលភាគីនីមួយៗមានហ៊ុន ដូចខាងក្រោម [redacted] ពីន មានហ៊ុន ៣៣%, សាន់ សឿន ៥៤% និងរស់ ណាំ ១៣% ដោយឈ្មោះ [redacted]ពីន ជាអ្នកឈរឈ្មោះ ក្នុងអាជ្ញាប័ណ្ណអគ្គិសនី ដូចមាននៅក្នុងកិច្ចសន្យាបែងចែកភាគហ៊ុន ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៨ នេះ ជាអង្គហេតុទទួលលើកឡើងរបស់ដើមចោទ។ ៣ ការមិនទទួលស្គាល់អង្គហេតុ៖ មូលហេតុនាំឱ្យមានការទិញហ៊ុន ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៩ ដោយសារដើមចោទ បានជំពាក់ប្រាក់ ចុងចម្លើយ ១៧០០០០ (ដប់ប្រាំពីរម៉ឺន) ដុល្លារអាមេរិក ក្នុងអំឡុងរកស៊ីអគ្គិសនីនេះ តាំងពីឆ្នាំ២០១៧ ដោយសារគ្មានប្រាក់សង និងគ្មានបំណងចង់បន្តអាជីវកម្មនេះតទៅមុខទៀត ទើបដើមចោទ សម្រេចចិត្តនៅចំពោះមុខបងប្អូនថាខ្លួនលក់ហ៊ុន ៥៤% នេះទៅឱ្យចុងចម្លើយក្នុងតម្លៃសរុប ៤៥៩០០០ (សែសិបប្រាំម៉ឺនប្រាំបួនពាន់) ដុល្លារអាមេរិក ដោយកាត់ប្រាក់ជំពាក់ខ្លួនចំនួន ៥០០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក ជាប្រាក់កក់ និងរក្សាប្រាក់ជំពាក់ នៅសល់ ១២០០០០ (ដប់ពីរម៉ឺន) ដុល្លារអាមេរិក ចាំទូទាត់នៅពេលបង់ប្រាក់ផ្តាច់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩។ ៤ មូលហេតុដែលដល់ថ្ងៃកំណត់ដែលត្រូវបង់ប្រាក់ឱ្យដើមចោទហើយ ចេះតែពន្យារពេល គឺដល់ថ្ងៃកំណត់បង់

ចុងចម្លើយ បានទំនាក់ទំនងទៅដើមចោទតាមរយៈទូរស័ព្ទ គាត់ថាគាត់មិនអាចចូលមកទទួលលុយនេះបានទេ ដោយសារមេធាវីគាត់រវល់ ទើបចុងចម្លើយឈ្មោះ [redacted] ពីន បានធ្វើលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ស្រាប់តែថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៩ មេធាវីរបស់គាត់ធ្វើលិខិតឆ្លើយតបមកវិញ។ ដោយសារបារម្ភពីការគេចវេះរបស់ចុងចម្លើយ ទើបលោក សុខពីន ធ្វើលិខិតជូនដំណឹងឆ្លើយតប នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ដោយជូនដំណឹងពីទីកន្លែងដែលត្រូវឆ្លើយតប គឺនៅអគ្គិសនី [redacted] ពីន។ ការលើកឡើងអង្គហេតុខាងលើ ភាគីម្ខាងទៀតមិនបានគេចវេះពីកាតព្វកិច្ច នៃការបង់ប្រាក់នោះទេ។ លើសពីនេះទៀត ប្រសិនបើដើមចោទមិនបានជំពាក់ប្រាក់ចុងចម្លើយ គាត់គ្មានមូលហេតុណាមួយចាំបាច់ត្រូវធ្វើកិច្ចសន្យាកក់ប្រាក់ លក់ភាគហ៊ុននោះទេ ហើយក៏គ្មានមូលហេតុដែលត្រូវប្តឹងសុំរំលាយកិច្ចសន្យា និងសុំស៊ីជាច់ប្រាក់កក់ ដែរ និងប្តឹងទៅនាយកដ្ឋានព្រហ្មទណ្ឌ ក្រសួងមហាផ្ទៃ ថាគេរំលោភយកភាគហ៊ុនរបស់ខ្លួន ៥៤% នោះដែរ តាមពាក្យបណ្តឹង ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៩។

-សេចក្តីថ្លែងការណ៍របស់ចុងចម្លើយឈ្មោះ [redacted] ពីនៈ មូលហេតុដែលមិនបានសរសេរប្រាក់ជំពាក់ចំនួន ១២០០០០ (ដប់ពីរម៉ឺន) ដុល្លារអាមេរិក នៅក្នុងកិច្ចសន្យាកក់ប្រាក់ ដោយសារ គាត់និយាយប្រាប់បងខ្លួន និងខ្លួនថាលុយ ១២០០០០ (ដប់ពីរម៉ឺន) ដុល្លារអាមេរិក នោះ ថា ពេលឱ្យលុយផ្តាច់ ចាំកាត់កងគ្នា និងប្រាក់ ១២០០០០ (ដប់ពីរម៉ឺន) ដុល្លារអាមេរិក នេះ ទុកស៊ីការប្រាក់ ។ តាំងពីខែមិថុនា មកខ្លួនមិនដែលទទួលបានភាគលាភពីដើមចោទឡើយ ព្រោះគាត់ជាអ្នកគ្រប់គ្រងទាំងអស់។

-សេចក្តីថ្លែងការណ៍របស់ដើមចោទឈ្មោះ [redacted] សឿន ៖ ខ្លួនពិតជាមិនទាន់បានបើកភាគលាភឱ្យគាត់មែន ព្រោះតែ [redacted] ពីន មិនចូលមកគិតបញ្ជីពីខែមករា មក។

-សេចក្តីថ្លែងការណ៍តប របស់មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទៈ ពាក់ព័ន្ធនឹងចំណុចទី៤ នៃពាក្យសុំកែតម្រូវ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ នោះ គឺមានន័យថា សុំរក្សាការអនុវត្តបណ្តោះអាសន្ន។ ទាក់ទងនឹងប្រាក់ ១៧០០០០ (ដប់ប្រាំពីរម៉ឺន) ដុល្លារអាមេរិក នេះ កូនក្តីខ្លួនសុំបដិសេធ មិនជំពាក់ទេ ដោយសារកូនក្តីខ្លួនមានការភ័ន្តច្រឡំ ដោយហេតុថា ជាការអះអាងផ្ទាល់មាត់ ពេលកូនក្តីខ្លួននៅក្រៅប្រទេស ហើយអាជីវកម្មមាន០៣កន្លែង ដោយឈ្មោះ [redacted] ពីន និងឈ្មោះ [redacted] សុខន ក្លែងបន្លំឯកសារ ទើបធ្វើឱ្យមានការកាត់កងគ្នា និងបញ្ចប់វិវាទតាមរយៈកិច្ចសន្យាបញ្ចប់វិវាទ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៨ ដែលមានស្នាមមេដៃ ១ [redacted] សុខន ២ [redacted] សឿន ៣ [redacted] ពីន ដែលមេធាវី ១ [redacted] ផល្លា ទី២ មេធាវី [redacted] បានឃើញនៅក្នុងកិច្ចសន្យាបញ្ចប់វិវាទ នេះផងដែរ។ ចំពោះការលើកឡើងថា មេធាវីរវល់ ក្នុងការប្រគល់ទទួលប្រាក់នោះ គឺជាការលើកឡើងដោយគ្មានមូលដ្ឋានគតិយុត្តិ។ ចំពោះការខកខានដែលមិនបានបង់ប្រាក់ឱ្យគ្រប់ចំនួន ដោយមានការជូនដំណឹងជាលាយលក្ខណ៍អក្សរនេះ គឺជាការបង្ហាញថាកូនបំណុលមិនអនុវត្តកាតព្វកិច្ច ដោយមានមេធាវី ចុះហត្ថលេខាដឹងលឺពីការមិនអនុវត្តកាតព្វកិច្ចគ្រប់ចំនួន គឺអនុវត្តតែប្រាក់ចំនួន ២៩៥០០០ (ម្ភៃប្រាំបីម៉ឺនប្រាំបួនពាន់) ដុល្លារអាមេរិក តែប៉ុណ្ណោះ។ ចំពោះករណីដែលកូនក្តីខ្លួន បានប្តឹងទៅក្រសួងមហាផ្ទៃពីការរំលោភភាគហ៊ុន ៥៤% ដោយហេតុថា ឈ្មោះ [redacted] ពីន មិនព្រមមកទទួលយកភាគលាភទៅតាមចំនួនភាគហ៊ុនរបស់ខ្លួន ហើយនឹងធ្វើការអះអាង ដោយផ្ទាល់មាត់ជាមួយគតិយជនផ្សេង គឺខ្លួនបានទិញយកភាគហ៊ុនរបស់អគ្គិសនី [redacted] ពីន ទាំងអស់រួចហើយ ទើបកូនក្តីខ្លួនមានការកើតទុក្ខមិនសុខចិត្ត ទើបឈានដល់ការដាក់ពាក្យបណ្តឹង។

-សេចក្តីថ្លែងការណ៍តប របស់មេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយៈ ឆ្លើយតបទៅនឹងកិច្ចសន្យាបញ្ចប់វិវាទ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលលើកឡើង ដោយដើមចោទ ជាបំណុលទាំងអស់បានបញ្ចប់ សួរថា តើដើមចោទ ពិតជាបានទទួលអង្គហេតុជំពាក់ប្រាក់ចុងចម្លើយ ប្រាកដមែន? ទី២ តាមខ្លឹមសារនៃកិច្ចសន្យា នេះ មិនបានឆ្លើយតប ឬបញ្ជាក់អំពីការទូទាត់ ឬការជម្រះបញ្ជីបំណុល រវាងដើមចោទ និងចុងចម្លើយ នោះទេ។ ពាក់ព័ន្ធនឹងអង្គហេតុជំពាក់ ខ្លួននឹងដាក់ជូនតុលាការពិនិត្យ និងសម្រេច។



Scanned with CamScanner

-សេចក្ដីថ្លែងការណ៍តប របស់មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ៖ កូនក្ដីខ្លួនសុំបដិសេធ បំណុល ព្រោះមានការភ័ន្តច្រឡំ ពេលដែលកូនក្ដីខ្លួននៅក្រៅប្រទេស។ បើសិនជាមានបញ្ជីគណនីជាលាយលក្ខណ៍អក្សរត្រឹមត្រូវ កូនក្ដីខ្លួនទទួលស្គាល់។

-សេចក្ដីថ្លែងការណ៍របស់ចុងចម្លើយ៖ ខ្លួនដាក់បណ្ដឹងតបនេះ គឺគោលបំណងរក្សាកិច្ចសន្យា ទុកជាបានការដដែល ហើយចំពោះចំណុចលំអិត ខ្លួនសុំទុកឱ្យមេធាវីខ្លួនថ្លែងការណ៍ជំនួសខ្លួន។

-សេចក្ដីថ្លែងការណ៍របស់មេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ៖ ចំពោះការទាមទារចំណុចទី១ នៃពាក្យបណ្ដឹងតប ដោយហេតុថា មុនដំបូងឡើយ កូនក្ដីខ្លួនរកស៊ីជាមួយនិង [redacted] សុខន, [redacted] សឿន ក្នុងម្នាក់ៗមានភាគហ៊ុន ៣៣,៣៣ភាគរយ។ ក្រោយមកអ្នកទាំងបីនាក់ បានព្រមព្រៀងបញ្ចប់វិវាទគ្នា ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៨ ដោយបានសម្រេចប្រគល់អាជីវកម្មអគ្គិសនីព្រែកអំពិល ទៅឱ្យ [redacted] សឿន និង [redacted] ពីន, និងប្រគល់អគ្គិសនីពត់សរ និងបាក់ដាវ ទៅឱ្យ [redacted] សុខន ចំណែកអគ្គិសនី បឹងខ្យាង ត្រូវបានបញ្ចប់កិច្ចសន្យាជួលជាមួយលោកស្រី [redacted] សុជាតី វិញ។ ចំពោះអគ្គិសនីព្រែកអំពិល ត្រូវបាន បែងចែកភាគហ៊ុនជាថ្មី ដោយឈ្មោះ [redacted] ពីន ៣៣% ឈ្មោះ សាន់ សឿន ៥៤% និងឈ្មោះ [redacted] ណាំ ១៣% ដូចមានបញ្ជាក់ក្នុងកិច្ចសន្យាបែងចែកភាគហ៊ុន ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៨។ ក្រោយមកទៀត ឈ្មោះ [redacted] សឿន បានប្រាប់កូនក្ដីខ្លួនមានបំណងចង់ទៅរស់នៅបរទេស វិញ និងមានបំណងមិនចង់រកស៊ីអគ្គិសនីតទៅទៀត ទើបគាត់លក់ភាគហ៊ុនគាត់ឱ្យកូនក្ដីខ្លួនក្នុងតម្លៃ ៤៥៩០០០ (សែសិបប្រាំម៉ឺនប្រាំបួនពាន់) ដុល្លារអាមេរិក ដោយកូនក្ដីខ្លួនបានកក់ប្រាក់ចំនួន ៥ម៉ឺនដុល្លារអាមេរិក នៅក្នុងថ្ងៃចុះកិច្ចសន្យាដោយមានបញ្ជាក់ក្នុងកិច្ចសន្យា ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៩។ ដោយសារតែក្នុងអំឡុងពេលនៃការប្រកបអាជីវកម្មជាមួយឈ្មោះ [redacted] សុខន ឆ្នាំ២០០៧ ឈ្មោះ [redacted] សឿន ដែលត្រូវជាបងប្រុសកូនក្ដីខ្លួន តែងតែបានខ្ចីប្រាក់ជាហូរហែ ដើម្បីបង្កើតដើមទុន សរុបចំនួន ១២ម៉ឺនដុល្លារ ប៉ុន្តែមិនបានធ្វើជាលាយលក្ខណ៍អក្សរ។ ហេតុដូច្នេះហើយ ទើបឈ្មោះ [redacted] សឿន និងកូនក្ដីខ្លួន បានព្រមព្រៀងគ្នាដោយមិនបានធ្វើជាលាយលក្ខណ៍អក្សរថា នៅថ្ងៃប្រគល់លុយបង្គ្រប់ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ អាចឱ្យកូនក្ដីខ្លួនដកប្រាក់ចំនួន ១២ម៉ឺនដុល្លារអាមេរិក ចេញពីថ្ងៃទិញលក់បង្គ្រប់បាន។ លុះដល់ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ កូនក្ដីខ្លួនបានជូនដំណឹងទៅលោក [redacted] សឿន ដើម្បីសុំអនុវត្តកាតព្វកិច្ចបង់ប្រាក់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ប៉ុន្តែឈ្មោះ [redacted] សឿន បានពន្យារពេលដោយលើកហេតុផលថា មេធាវីមិនអាចចូលរួមបាន និងរវល់ ហេតុដូច្នេះ កូនក្ដីខ្លួនបានជូនដំណឹងជាលាយលក្ខណ៍អក្សរ ដោយកំណត់ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៩ ម៉ោង ២រសៀល នៅការិយាល័យមេធាវី [redacted] ដោយមានបងប្អូនចូលរួមដឹងលឺ ផងដែរ។ នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៩ កូនក្ដីខ្លួនបានទទួលលិខិតជូនដំណឹងពីលោកមេធាវី [redacted] ឱ្យអនុវត្តកិច្ចសន្យាប្រាក់កក់ខាងលើ ក្នុងថ្ងៃកំណត់ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។ បន្ទាប់ពីកូនក្ដីខ្លួន ទទួលលិខិតជូនដំណឹងពីលោកមេធាវីរួច កូនក្ដីខ្លួនមានចេតនាបន្តនូវការបង់ប្រាក់ ប៉ុន្តែនៅក្នុងលិខិតជូនដំណឹងនោះ មិនបានកំណត់ពេលវេលា និងទីកន្លែងឱ្យច្បាស់លាស់ ដើម្បីឱ្យកូនក្ដីខ្លួនអនុវត្តកាតព្វកិច្ចបង់ប្រាក់ឡើយ។ទើបកូនក្ដីខ្លួនជូនដំណឹងទៅឱ្យឈ្មោះ [redacted] សឿន វិញ ដោយស្នើសុំឱ្យគាត់មកទទួលប្រាក់បង្គ្រប់នៅទីស្នាក់ការអគ្គិសនី [redacted] ពីន ស្ថិតនៅភូមិព្រែកក្របៅទី៣ ឃុំព្រែកអំពិល ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល វេលាម៉ោង ៣រសៀល ដែលជាទីកន្លែងប្រកបអាជីវកម្មរួមគ្នា រវាងកូនក្ដីខ្លួន និងឈ្មោះ សាន់ សឿន។ ផ្ទុយមកវិញ កូនក្ដីខ្លួនបានទទួលលិខិតជូនដំណឹង ដាច់ប្រាក់កក់ និងបញ្ចប់កិច្ចសន្យា ប្រាក់កក់ពីលោកមេធាវី [redacted] ទៅវិញ ទាំងដែលកូនក្ដីខ្លួន ព្យាយាមអនុវត្តនូវកាតព្វកិច្ចបង់ប្រាក់ជាច្រើនលើកច្រើនសារដូចបានរៀបរាប់ខាងលើ ហើយឈ្មោះ [redacted] សឿន តែងតែគេចវេះ មិនទទួលប្រាក់បង្គ្រប់ពីកូនក្ដីខ្លួនផងនោះ។ តាមរយៈការរៀបរាប់ខាងលើនេះ បញ្ជាក់ឱ្យឃើញថា កូនក្ដីខ្លួន មិនមានកំហុសក្នុងការអនុវត្តកាតព្វកិច្ចតាមកិច្ច

សន្យាកក់ប្រាក់ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៩ ឡើយ។ ហើយកូនក្តីខ្លួននៅតែមានបំណងទទួលទិញយកភាគហ៊ុន ចំនួន ៥៤% ពីឈ្មោះ [redacted] សឿន ដដែល។ ចំពោះការទាមទារចំណុចទី៣ ទី៤ នៅក្នុងពាក្យបណ្តឹងតបកូនក្តីខ្លួនរក្សាការទាមទារដូចមានក្នុងបណ្តឹងតប ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៩ និងសេចក្តីថ្លែងការណ៍ក្នុងឯកសារ ត្រៀម ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២០ របស់មេធាវី [redacted] និងមេធាវី [redacted]

-សេចក្តីថ្លែងការណ៍តប របស់មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ៖ ខ្លួនសុំច្រានចោលពាក្យបណ្តឹងតប ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៩ ដោយហេតុថា កាតព្វកិច្ចនៃការបង់ប្រាក់ ដូចបានលើកឡើងខាងលើគឺផ្ទុយពីកិច្ចសន្យាកក់ប្រាក់ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៩។ ក្រោយពីមានការយឺតយ៉ាវ ក្នុងការបង់ប្រាក់បង្គ្រប់កូនក្តីខ្លួនតាមរយៈការជូនដំណឹងរបស់មេធាវីឈ្មោះ [redacted] បញ្ញា ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ គឺបង់ប្រាក់ឱ្យកូនក្តីខ្លួនខ្វះ ដោយបង់តែចំនួន ២៨៩០០០ (ម្ភៃប្រាំបីម៉ឺនប្រាំបួនពាន់) ដុល្លារអាមេរិក ទើបកូនក្តីខ្លួន ធ្វើលិខិតជូនដំណឹងឱ្យអនុវត្តកិច្ចសន្យា ដោយបង់ប្រាក់បង្គ្រប់ តែដើមបណ្តឹងតប នៅតែមិនបង់ប្រាក់ឱ្យគ្រប់ចំនួនដដែល ទើបកូនក្តីខ្លួនជូនដំណឹងអំពីការដាច់ប្រាក់កក់ និងបន្តបន្ទាប់ ជូនដំណឹងអំពីការលុបកិច្ចសន្យាទិញលក់ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៩ យោងទៅលើការជូនដំណឹងនៅក្នុងនីតិវិធីនៃការជូនដំណឹង របស់កូនក្តីខ្លួន គឺធ្វើឡើងតាមទម្រង់ច្បាប់។ មកដល់បច្ចុប្បន្ននេះ កូនក្តីខ្លួននៅតែរក្សាតាមពាក្យបណ្តឹង ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៩ និងពាក្យសុំកែតម្រូវពាក្យបណ្តឹង ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ទុកជាបានការ ដោយហេតុថា នេះមិនមែនជាកំហុសរបស់កូនក្តីខ្លួន ក្នុងការមិនទទួលប្រាក់នោះទេ ដោយសារតែដើមបណ្តឹងតប មិនបំពេញកាតព្វកិច្ចឱ្យគ្រប់ចំនួនទឹកប្រាក់ដែលត្រូវបង់ គឺ ៤០៩០០០ (សែសិបម៉ឺនប្រាំបួនពាន់) ដុល្លារអាមេរិក។

-សេចក្តីថ្លែងការណ៍តប របស់មេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ៖ ចំពោះការអនុវត្តកាតព្វកិច្ចរបស់កូនក្តីខ្លួន គឺមិនមានកំហុសទេ ដោយហេតុថា ទី១ នៅក្នុងទំនាក់ទំនងរវាងកូនក្តីខ្លួន និង [redacted] សឿន គឺជាបងប្អូនបង្កើតដែលជាទូទៅ គឺច្រើនតែការធ្វើកិច្ចសន្យា ឬធ្វើសកម្មភាពផ្សេងៗ គឺច្រើនតែធ្វើឡើងដោយផ្ទាល់មាត់។ ទី២ ក្នុងវិស័យជំនួញជួញដូរ ដែលច្រើនអនុវត្តទូទៅនៅប្រទេសកម្ពុជា នាពេលបច្ចុប្បន្ន គឺតែងតែទុកចិត្តគ្នា និងអនុវត្តការរកស៊ីតាមទំនៀមទំលាប់។ ទី៣ កន្លងមក នៅក្នុងការរកស៊ីរវាងកូនក្តីខ្លួន និងឈ្មោះ [redacted] សឿន គឺឈ្មោះ [redacted] សឿន តែងឱ្យកូនក្តីខ្លួន ធ្វើនេះធ្វើនោះ តាមរយៈផ្ទាល់មាត់ដែរ។ តាមរយៈការលើកឡើងទាំង០៣ ចំណុចនេះ គឺអាចបញ្ជាក់បានថាកូនក្តីខ្លួន និងឈ្មោះ [redacted] សឿន ពិតជាមានការព្រមព្រៀងដោយផ្ទាល់មាត់ ឱ្យកូនក្តីខ្លួនដកប្រាក់ដែលខ្លួនបានជំពាក់ចេញពីប្រាក់បង់ថ្លៃបង្គ្រប់ទាំងអស់ពិតប្រាកដមែន ទើបកូនក្តីខ្លួន នៅតែរក្សាគោលជំហរយ៉ាងម៉ឺងម៉ាត់បង់ប្រាក់បង្គ្រប់តែ ២៨៩០០០ (ម្ភៃប្រាំបីម៉ឺនប្រាំបួនពាន់) ដុល្លារអាមេរិក ចាត់តាំងពីមានវិវាទកើតឡើងរហូតដល់មានពាក្យបណ្តឹងនេះ។ ជាពិសេស ការសន្យានេះក៏ត្រូវបានបងប្អូនដឹងលឺ ដែលពួកគាត់នឹងធ្វើជាសាក្សីក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់។ តាមរយៈនេះ កូនក្តីខ្លួននៅតែរក្សាបណ្តឹងតបខាងលើដដែល។

-សាក្សីឈ្មោះ [redacted] ផាន់នី បានអះអាងថា៖ ដើមចោទ មានភាគហ៊ុន ៥៤% ហើយកន្លងមក ធ្លាប់និយាយថា ជំពាក់លុយ ហើយរកស៊ីពិបាកណាស់ ហើយគាត់ចង់ទៅរស់នៅស្រុកក្រៅវិញ ក៏គាត់សម្រេចចិត្តលក់ភាគហ៊ុនឱ្យប្អូន ដោយលក់ក្នុងតម្លៃ ៨០ម៉ឺនដុល្លារអាមេរិក ហើយប្អូនក៏ទិញរួចក៏ចាប់ផ្តើមកក់ប្រាក់ចំនួន ៥ម៉ឺនដុល្លារអាមេរិក ហើយពេលបង់ប្រាក់បង្គ្រប់ ដោយដកកលុយជំពាក់ ១២ម៉ឺនដុល្លារអាមេរិក ចេញ។ ពេលកក់ប្រាក់នោះ ខ្លួនធ្វើជាសាក្សីខាងអ្នកលក់ ដោយកិច្ចសន្យានោះធ្វើនៅទីណា ខ្លួនមិនចាំទេ ព្រោះឆ្ងាយដែរ។ ការកក់ប្រាក់នោះ គឺគ្មានភូមិឃុំដឹងលឺនោះទេ ដោយមានការចូលរួមតែបងប្អូនប៉ុណ្ណោះ។ តម្លៃ ៨០ម៉ឺនដុល្លារអាមេរិក នោះ គឺតម្លៃទាំងអចលនទ្រព្យ ហើយគេបូកដកចេញមក ខ្លួនមិនចេះទេ ដឹងថាថ្លៃអគ្គិសនីនោះ ប្រហែល ៤០ម៉ឺនដុល្លារអាមេរិកជាង។ នៅថ្ងៃទី៣០ ជាថ្ងៃប្រគល់លុយ ប្រពន្ធរបស់ឈ្មោះ [redacted] ពីន ក៏មកយកខ្លួន ហើយនាំគ្នាចាំ [redacted] សឿន នៅការិយាល័យអគ្គិសនី មកទទួលប្រាក់ ប៉ុន្តែមិនឃើញ [redacted] សឿន មកទេ ខ្លួនមិនដឹង

មូលហេតុអ្វីនោះទេ។ ខ្លួនក៏ត្រឡប់មកផ្ទះវិញ។ ខ្លួនមិនដឹងថា ការរកស៊ីខាត ឬចំណេញ នោះទេ។ ឈ្មោះ [redacted] សឿន តែងតែឡើងចុះក្រៅប្រទេស។ ការរកស៊ីនោះ គឺរកស៊ីយូរមកហើយ តាំងពីសម័យ [redacted] សុខន ដូចនេះ មានការជំពាក់គេច្រើន ហើយគាត់ចង់រស់នៅក្រៅប្រទេសផង ក៏គាត់លក់ភាគហ៊ុនឱ្យប្អូនទៅ ហើយប្អូន គាត់ទិញយកភាគហ៊ុននោះ ព្រោះគេមានដើមទុនច្រើន។ លុយចំនួន ១២ម៉ឺនដុល្លារនោះ គឺទូទាត់សងនៅពេលបង់ប្រាក់បង្គ្រប់។ នៅថ្ងៃប្រគល់លុយនោះ គឺ [redacted] ពីន មានលុយ ២៨ម៉ឺនដុល្លារអាមេរិក។

-សាក្សីឈ្មោះ [redacted] យ៉ីន បានអះអាងថា៖ ខ្លួនត្រូវជាបងប្អូនបង្កើតឈ្មោះ [redacted] ពីន និងឈ្មោះ [redacted] សឿន។ លុយជំពាក់ចំនួន ១២ម៉ឺនដុល្លារអាមេរិកនោះ គឺនឹងកាត់កងគ្នាពេលប្រគល់លុយបង្គ្រប់។ ខ្លួនធ្វើការនៅអគ្គិសនីនោះ ជាមួយ [redacted] សឿន និង [redacted] ពីន ដែរ ហើយប្ដីខ្លួនមានភាគហ៊ុននៅទីនោះដែរ។ ប្ដីខ្លួនរកស៊ីខាចតិចតួច។ ប្ដីខ្លួនមានភាគហ៊ុន ១៣%។ ចំពោះបញ្ជីចំណាយ ខ្លួនមិនដែលដឹងទេ។ ចំពោះលុយខាត គឺ [redacted] សឿន គាត់ខ្ចី [redacted] ពីន។ លុយជំពាក់ ១២ម៉ឺនដុល្លារអាមេរិក គឺនឹងកាត់កងនៅពេលបង់ប្រាក់បង្គ្រប់ ដូច្នេះលុយត្រូវឱ្យចំនួនប្រហែល ២៨ម៉ឺនដុល្លារអមេរិក។ ចំពោះបញ្ជីចំណូលចំណាយ ខ្លួនមិនសូវដឹងនោះទេ។

-សាក្សីឈ្មោះ [redacted] ណាំ បានអះអាងថា ខ្លួនត្រូវជាសាច់ថ្លៃរបស់ [redacted] ពីន និង [redacted] សឿន និងត្រូវជាប្ដីរបស់ឈ្មោះ [redacted] យ៉ីន។ ដំបូងឡើយ មានការរកស៊ីខាត ក៏ឱ្យអ្នកមានភាគហ៊ុនទាំងអស់បង់លុយខាតទៅតាមភាគហ៊ុននីមួយៗ ហើយឈ្មោះ [redacted] សឿន ត្រូវចេញចំនួន ១៧ម៉ឺន ដុល្លារអាមេរិក ពីឈ្មោះ [redacted] ពីន ព្រោះ [redacted] ពីន មានលុយច្រើនជាង យកមកដាក់ក្នុងហ៊ុន។ ពេលប្រគល់លុយ ១៧ម៉ឺនដុល្លារអាមេរិក នោះ ខ្លួននៅទីនោះដែរ។ ពេលនោះគ្មានលុយ ១៧ម៉ឺនដុល្លារអាមេរិក សុទ្ធនោះទេ គឺមានតែក្រដាស។ ក្រោយពេលដែលបែងចែកហើយ គឺខ្លួន ១៣% សុខពីន ៣៣% និងសាន់សឿន ៥៤%។ បន្ទាប់មក អ្នកណាដែលមិនជំពាក់គេនោះ គឺទទួលបានប្រាក់ចំណេញ ចំណែកអ្នកដែលនៅជំពាក់គេនោះ គឺត្រូវកាត់កងជាមួយប្រាក់ចំណេញ។ ឈ្មោះ [redacted] សឿន ពិតជាបានលក់ភាគហ៊ុន ៥៤% ឱ្យទៅឈ្មោះ [redacted] ពីន។ ភាគហ៊ុន ១០០% គឺ ៨៥ម៉ឺនដុល្លារអាមេរិក ដូច្នេះកាត់កងទៅភាគហ៊ុន ៥៤% នោះ មានតម្លៃប្រហែល ៤១ម៉ឺនដុល្លារអាមេរិក ហើយ សុខពីន ក៏កាត់កងប្រាក់ជំពាក់ ១៧ម៉ឺនដុល្លារអាមេរិក នោះ ដោយកាត់ប្រាក់កក់ លើកិច្ចសន្យាលក់ទិញភាគហ៊ុនចំនួន ៥ម៉ឺនដុល្លារអាមេរិក ហើយនៅសល់ប្រហែល ១២ម៉ឺនដុល្លារ នឹងត្រូវកាត់កងនៅពេលបង់ប្រាក់បង្គ្រប់ ដោយត្រូវបង់ប្រាក់ចំនួន ២៨៥០០០ (ម្ភៃប្រាំបីម៉ឺនប្រាំបួនពាន់) ដុល្លារអាមេរិក នៅក្នុងកិច្ចសន្យានោះ មិនបានសរសេរទឹកប្រាក់ដែលត្រូវបង់បង្គ្រប់ទេ។ នៅថ្ងៃដែលប្រគល់ប្រាក់បង្គ្រប់នោះ ខ្លួនដឹងថា [redacted] ពីន ឱ្យ [redacted] សឿន ចំនួន ២៨៥០០០ ដុល្លារអាមេរិក កាត់កងចេញពីបំណុលចំនួន ១២ម៉ឺនដុល្លារ។ នៅក្នុងលិខិតដើម គឺសរសេរលុយ ៥ម៉ឺនដុល្លារ និងមិនបានសរសេរកាត់កងលុយ ១២ម៉ឺនដុល្លារទេ។ ពេលគាត់ចរចាគ្នានោះ គឺឈ្មោះ [redacted] សឿន សន្យាដោយផ្ទាល់មាត់ ដោយនឹងកាត់បំណុល ១២ម៉ឺនដុល្លារ ពេលបង់ប្រាក់ បង្គ្រប់។ ពេលទម្លាក់បញ្ជីនោះ គឺនៅឆ្នាំ២០១៧។ ស្ថានភាពបច្ចុប្បន្ន គឺមានការចំណេញតិចៗហើយ ប៉ុន្តែនៅមានបញ្ហារឿងកិច្ចសន្យាលក់ភាគហ៊ុននេះ។ ចាប់ពីពេលទម្លាក់បញ្ជីចូលឆ្នាំ២០១៧ ហើយបានទូទាត់បំណុលរួចជាបណ្ដើរៗហើយ។ បច្ចុប្បន្ននេះ ខ្លួនឃើញថា ឈ្មោះ [redacted] សឿន និងឈ្មោះ [redacted] ពីន មិនអាចបន្តការរកស៊ីនឹងគ្នាតទៅទៀតទេ ព្រោះសូម្បីតែខ្លួនមានបញ្ជីហើយ ក៏ [redacted] សឿនរករឿងខ្លួនដែរ។ ពេលរកស៊ី ០៣នាក់ ក្រោយនេះ ចាប់ផ្ដើមអាជីវកម្មចំណេញ។

-សាក្សីឈ្មោះ [redacted] សុខន បានអះអាងថា បច្ចុប្បន្ននេះ ខ្លួនបានបញ្ឈប់ការរកស៊ីជាមួយបងប្អូនគាត់នោះហើយ។ ពេលរកស៊ី គឺយើងដាក់ចូលហ៊ុន ដើម្បីស៊ីការប្រាក់ តាមចំណែករៀងៗខ្លួន ខ្ចះប៉ុន្មាន គឺខ្ចីធនាគារ ប៉ុន្តែការប្រាក់ គឺច្រើនពេក ទើបធ្វើឱ្យខាត។ ការដាក់លុយឱ្យចូលរកស៊ីនោះ គឺដាក់ម្ដងបន្តិចៗ ដោយខ្លួនមិនចាំឆ្នាំ ដាក់លុយដំបូងទេ។ ពេលមុននោះ ក៏ [redacted] សឿន ចេញចូលៗក្រៅប្រទេសដូចសព្វថ្ងៃដែរ ឈ្មោះ [redacted] សឿន មិនដែលបានចុះប្រមូលលុយទេ គឺឈ្មោះ [redacted] ពីន ជាអ្នកប្រមូល ជាមួយ [redacted] ណាំ ហើយខ្លួនប្រមូលខ្លះ និង



Scanned with CamScanner

គិតគួរបញ្ជី ដើម្បីយកលុយទៅបង់ថ្លៃភ្លើងគេ។ ពេលចូលហ៊ុនដំបូង គឺ [redacted] ពីន នៅលីវ មិនទាន់រៀបការទេ។ ពេលទូទាត់បញ្ចប់ចប់ចុងក្រោយ គឺមិនមានជំពាក់លុយរដ្ឋទេ គឺបង់អស់ហើយ និងបែងចែកអគ្គិសនីគ្នាកាន់ច្បាស់លាស់អស់ហើយ។ កាលពីមុន [redacted] ពីន គាត់ប្រមូលលុយបាន ហើយគាត់មិនយកឱ្យខ្លួនទេ បន្ទាប់មកក៏គេរកបិទភ្លើង បន្ទាប់មក គំដោះស្រាយគ្នា ខ្លួនមិនដឹង [redacted] ពីន ធ្វើតាមនរណាទេ បន្ទាប់មក [redacted] ពីន ក៏យកលុយមកបង់ឱ្យខ្លួន ហើយខ្លួនក៏យកទៅបង់ថ្លៃភ្លើងឱ្យគេបន្ត។ ឈ្មោះ [redacted] សឿន គឺចេញចូលក្រៅប្រទេសរហូត គាត់មិនសូវបានចូលប្រមូលទេ ប៉ុន្តែបើគាត់ប្រមូលបាន គាត់តែងតែប្រាប់ខ្លួនថា ប្រមូលលុយបានប៉ុណ្ណេះ ខ្លួនកត់ចូលបញ្ជី។ បច្ចុប្បន្នការរកស៊ី គឺល្អប្រសើរ មិនមានបញ្ហាទេ ព្រោះយើងបានទូទាត់បំណុលរួចហើយ។ ចំពោះការជំពាក់ប្រាក់រវាង [redacted] សឿន និង [redacted] ពីន ខ្លួនមិនដឹងអ្វីទេ។ ពេលរកស៊ីជាមួយខ្លួន ការខាតបង់នានា គឺមានបញ្ជីច្បាស់លាស់រាល់ខែ។

-សេចក្ដីថ្លែងការណ៍របស់ចុងចម្លើយឈ្មោះ [redacted] ពីន៖ ខ្លួនមិនអាចបន្តការរកស៊ីជាមួយគាត់ទៀតបានទេ។ ពេលនេះ ខ្លួនសុខចិត្តបង់លុយចំនួន ៤០៩០០០ (សែសិបម៉ឺនប្រាំបួនពាន់) ដុល្លារអាមេរិក តាមកិច្ចសន្យា។ ខ្លួនរៀបការនៅឆ្នាំ២០១៣។ ការខ្ចីលុយខាងប្រពន្ធ គឺខ្លួនមានឯកសារលាយលក្ខណ៍អក្សរ ចំណែកឯ ការខ្ចីជំពាក់ប្រាក់ជាមួយបង [redacted] សឿន ខ្លួនមិនបានធ្វើជាលាយលក្ខណ៍អក្សរនោះទេ ព្រោះខ្លួនយល់ថា គាត់ជាបងប្អូន។ លុយដែលគាត់ប្រមូលបាន គាត់មិនបានទៅបង់ភ្លើងនៅក្រុមហ៊ុនអានកូ ទេ ដូច្នេះ វាប៉ះពាល់ដល់ឈ្មោះ ខ្លួនដែលមានឈ្មោះក្នុងអាជ្ញាប័ណ្ណ ហើយគេហៅខ្លួនទៅបង់លុយ បើមិនបង់ទេ គឺគេនឹងផ្ដាច់ភ្លើង។

-សេចក្ដីថ្លែងការណ៍របស់ដើមចោទឈ្មោះ [redacted] សឿន៖ ខ្លួនមិនបានទៅបង់នៅក្រុមហ៊ុនអានកូ ព្រោះខ្លួនបានដាក់ពាក្យសុំខ្ចីលុយ រ៉េះ ហើយ [redacted] ពីន មិនបានមកស៊ីញ៉េឱ្យ ដូច្នេះ គាត់ខាង រ៉េះ គេមិនទម្លាក់លុយឱ្យ។

-សេចក្ដីថ្លែងការណ៍របស់ចុងចម្លើយ៖ ខ្លួនមិនទៅស៊ីញ៉េ នៅ រ៉េះ ឱ្យ ព្រោះអាជ្ញាប័ណ្ណឈ្មោះ ខ្លួន បើខ្លួនទៅស៊ីញ៉េឱ្យគាត់ ហើយគាត់យកលុយទៅបាត់ ឱ្យខ្លួនធ្វើយ៉ាងម៉េះ មិនខ្លួនជាអ្នកទទួលខុសត្រូវ។

-សេចក្ដីថ្លែងការណ៍របស់ដើមចោទ៖ ខ្លួនមិនព្រមទទួលយកលុយជាង៤០ម៉ឺនដុល្លារអាមេរិក នោះទេ។

៥) ចំណុចវិវាទ:

៥.១- មូលហេតុចាំបាច់ នៃការសុំរំលាយកិច្ចសន្យា និងការបន្ត នៃកិច្ចសន្យា?

៥.២. ការអនុវត្តកាតព្វកិច្ចរបស់អ្នកលក់ និងការអនុវត្តកាតព្វកិច្ចរបស់អ្នកទិញ?

៥.៣. ការទាមទារជម្ងឺចិត្តរបស់ភាគី ពិចារណាទៅតាមព្យសនកម្មជាក់ស្ដែង?

៥.៤. ការលើកឡើងសុំអនុវត្តជាបណ្ដោះអាសន្ន?

## <u>សំអាងហេតុ</u>

-តាមលទ្ធផលនៃការសាកសួរសាមីភាគី និងពិនិត្យភស្តុតាងក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ឃើញថា ៖

១- មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទបានថ្លែងការណ៍ថា កូនក្តីខ្លួនពិតជាបានចុះកិច្ចសន្យាទិញលក់ភាគហ៊ុន ៥៤% នៃអគ្គិសនី ២០៩អ ក្នុងតម្លៃ ៤៥៩០០០ (សែសិបប្រាំម៉ឺនប្រាំបួនពាន់) ដុល្លារអាមេរិក ដោយកក់ប្រាក់ចំនួន ៥០០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក និងកំណត់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ដើម្បីបង់ប្រាក់បង្គ្រប់។ មកដល់កំណត់ ចុងចម្លើយមិនបានយកលុយមកបង់ទេ ដោយបានជូនដំណឹងតាមរយៈមេធាវីថាត្រូវបង់តែ ២៨៩០០០ (ម្ភៃប្រាំបីម៉ឺនប្រាំបួនពាន់) ដុល្លារអាមេរិក ទេ ហេតុនេះ កូនក្ដីខ្លួន ក៏បដិសេធមិនទទួលយកប្រាក់នេះ ឬព័ត៌មាននេះទេ ហើយបានជូនដំណឹងត្រឡប់ទៅវិញ នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៩ កូនក្ដីខ្លួនបានជូនដំណឹងទៅចុងចម្លើយ ឱ្យបង់លុយ ៤០៩០០០ (សែសិបម៉ឺនប្រាំបួនពាន់) ដុល្លារអាមេរិក ទើបកូនក្ដីខ្លួនទទួលយក ប៉ុន្តែចុងចម្លើយមិនព្រម និងជូនព័ត៌មានថា ខ្លួននៅតែបង់ ២៨៩០០០ (ម្ភៃប្រាំបីម៉ឺនប្រាំបួនពាន់)

ដុល្លារអាមេរិក ដដែល។ ក្រោយពីផុតរយៈពេល នៃការកំណត់កូនក្ដីខ្លួនបានជូនដំណឹងជាលាយលក្ខណ៍អក្សរ អំពីការបញ្ចប់កិច្ចព្រមព្រៀងទិញលក់ ៥៤% នៃអគ្គិសនី [redacted] ពីន និងសុំដាច់ប្រាក់កក់ចំនួន ៥០០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក នោះ។ ចំណែកឯ បច្ចុប្បន្ន ភាគហ៊ុន ៥៤% និងប្រតិបត្តិការជានា គឺកូនក្ដីខ្លួន កាន់កាប់ជាធម្មតា។ ចំពោះភាគហ៊ុនរបស់ចុងចម្លើយ ៣៣% រក្សាដដែល និងទទួលបានភាគហ៊ុនជាប្រចាំខែធម្មតា តាមរយៈការដកក្នុងថវិកាដែលអតិថិជន បានបង់។ ទាក់ទងនឹងមូលហេតុ សុំរំលាយកិច្ចសន្យាទិញភាគហ៊ុននេះ ដោយសារតែភាគីអ្នកទិញ មិនអនុវត្តកាតព្វកិច្ចនៃការបង់ប្រាក់ និងកូនក្ដីខ្លួនបានជូនដំណឹងពីការបញ្ចប់កិច្ចសន្យា និងជូនដំណឹងពីការដាច់ប្រាក់កក់ រួចរាល់ហើយ និងចំពោះសកម្មភាពនៃការគ្រប់គ្រងប្រតិបត្តិការនេះ គឺនៅធម្មតា។

២-មេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ ៖ សុំច្រានចោលការទាមទារគ្រប់ចំណុចនៃការទាមទាររបស់ដើមចោទទាំងអស់ និងមិនទទួលស្គាល់អង្គហេតុ ដែលដើមចោទបានលើកឡើងអំពីការទិញហ៊ុន។ មូលហេតុនាំឱ្យមានការទិញហ៊ុន ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៩នោះ ដោយសារដើមចោទបានជំពាក់ប្រាក់ ចុងចម្លើយ ១៧០០០០ (ដប់ប្រាំពីរម៉ឺន) ដុល្លារអាមេរិក ក្នុងអំឡុងរកស៊ីអគ្គិសនីនេះ តាំងពីឆ្នាំ២០១៧ ដោយសារគ្មានប្រាក់សង និងគ្មានបំណងចង់បន្តអាជីវកម្មនេះតទៅមុខទៀត ទើបដើមចោទ សម្រេចចិត្តនៅចំពោះមុខបងប្អូនថា ខ្លួនលក់ហ៊ុន ៥៤% នេះទៅឱ្យចុងចម្លើយក្នុងតម្លៃសរុប៤៥៩០០០ (សែសិបប្រាំម៉ឺនប្រាំបួនពាន់) ដុល្លារអាមេរិក ដោយកាត់ប្រាក់ជំពាក់ខ្លួនចំនួន ៥០០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក ជាប្រាក់កក់ និងរក្សាប្រាក់ជំពាក់ នៅសល់ ១២០០០០ (ដប់ពីរម៉ឺន) ដុល្លារអាមេរិក ចាំទូទាត់នៅពេលបង់ប្រាក់ផ្ដាច់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩។ ចំពោះថ្ងៃកំណត់ដែលត្រូវបង់ប្រាក់ឱ្យដើមចោទហើយ ចេះតែពន្យារពេល គឺដល់ថ្ងៃកំណត់បង់ ចុងចម្លើយ បានទំនាក់ទំនងទៅដើមចោទតាមរយៈទូរស័ព្ទ គាត់ថាគាត់មិនអាចចូលមកទទួលលុយនេះបានទេ ដោយសារមេធាវីគាត់រវល់ ទើបចុងចម្លើយឈ្មោះ [redacted] ពីន បានធ្វើលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ ២០១៩ ស្រាប់តែថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៩ មេធាវីរបស់គាត់ធ្វើលិខិតឆ្លើយតបមកវិញ។ ដោយសារបារម្ភពីការគេចវេះរបស់ចុងចម្លើយ ទើបលោក [redacted]ពីន ធ្វើលិខិតជូនដំណឹងឆ្លើយតប នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ២០១៩ ដោយជូនដំណឹងពីទីកន្លែងដែលត្រូវឆ្លើយតប គឺនៅអគ្គិសនី [redacted] ពីន។ ការលើកឡើងអង្គហេតុខាងលើ ភាគីអ្នកទិញ មិនបានគេចវេះពីកាតព្វកិច្ច នៃការបង់ប្រាក់នោះទេ។ លើសពីនេះទៀត ប្រសិនបើដើមចោទមិនបានជំពាក់ប្រាក់ចុងចម្លើយ គាត់គ្មានមូលហេតុណាមួយចាំបាច់ត្រូវធ្វើកិច្ចសន្យាកក់ប្រាក់ លក់ភាគហ៊ុននោះទេ ហើយក៏គ្មានមូលហេតុដែលត្រូវប្ដឹងសុំរំលាយកិច្ចសន្យា និងសុំស៊ីដាច់ប្រាក់កក់ដែរ និងប្ដឹងទៅនាយកដ្ឋានព្រហ្មទណ្ឌ ក្រសួងមហាផ្ទៃ ថាគេរំលោភយកភាគហ៊ុនរបស់ខ្លួន ៥៤% នោះដែរ តាមពាក្យបណ្ដឹង ចុះថ្ងៃទី ២៩ ខែសីហា ឆ្នាំ២០១៩។ ម្យ៉ាងទៀត ចុងចម្លើយឈ្មោះសុខ ពីន បានអះអាងថា មូលហេតុដែលមិនបានសរសេរប្រាក់ជំពាក់ចំនួន ១២០០០០ (ដប់ពីរម៉ឺន) ដុល្លារអាមេរិក នៅក្នុងកិច្ចសន្យាកក់ប្រាក់ ដោយសារ ដើមចោទនិយាយប្រាប់បងខ្លួន និងខ្លួនថាលុយ ១២០០០០ (ដប់ពីរម៉ឺន) ដុល្លារអាមេរិក នោះ ថា ពេលឱ្យលុយផ្ដាច់ ចាំកាត់កងគ្នា និងប្រាក់ ១២០០០០ (ដប់ពីរម៉ឺន) ដុល្លារអាមេរិក នេះ ទុកស៊ីការប្រាក់ ។ តាំងពីខែមិថុនា មកខ្លួនមិនដែលទទួលបានភាគលាភពីដើមចោទឡើយ ព្រោះគាត់ជាអ្នកគ្រប់គ្រងទាំងអស់។ ផ្ទុយទៅវិញ មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទបានបដិសេធថា៖ ទាក់ទងនឹងប្រាក់ ១៧០០០០ (ដប់ប្រាំពីរម៉ឺន) ដុល្លារអាមេរិក នេះ កូនក្ដីខ្លួន មិនជំពាក់ទេ ដោយសារកូនក្ដីខ្លួនមានការភ័ន្តច្រឡំ ដោយហេតុថា ជាការអះអាងផ្ទាល់មាត់ ពេលកូនក្ដីខ្លួននៅក្រៅប្រទេស ហើយអាជីវកម្ម មាន០៣កន្លែង ដោយឈ្មោះ [redacted] ពីន និងឈ្មោះ [redacted] សុខន ក្លែងបន្លំឯកសារ ទើបធ្វើឱ្យមានការកាត់កងគ្នា និងបញ្ចប់វិវាទតាមរយៈកិច្ចសន្យាបញ្ចប់វិវាទ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៨ ដែលមានស្នាមមេដៃ ១ [redacted] សុខន ២ [redacted] សឿន ៣ [redacted] ពីន ដែលមេធាវី ១ [redacted] ផល្លា ទី២ មេធាវី [redacted] បានឃើញនៅក្នុងកិច្ចសន្យាបញ្ចប់វិវាទ នេះផងដែរ។ ចំពោះការលើកឡើងថា មេធាវី

វល់ ក្នុងការប្រគល់ទទួលប្រាក់នោះ គឺជាការលើកឡើងដោយគ្មានមូលដ្ឋានគតិយុត្តិ។ ចំពោះការខកខានដែលមិនបានបង់ប្រាក់ឱ្យគ្រប់ចំនួន ដោយមានការជូនដំណឹងជាលាយលក្ខណ៍អក្សរនេះ គឺជាការបង្ហាញថាកូនបំណុលមិនអនុវត្តកាតព្វកិច្ច ដោយមានមេធាវី ចុះហត្ថលេខាដឹងលឺពីការមិនអនុវត្តកាតព្វកិច្ចគ្រប់ចំនួន គឺអនុវត្តតែប្រាក់ចំនួន ២៨៥០០០ (ម្ភៃប្រាំបីម៉ឺនប្រាំបួនពាន់) ដុល្លារអាមេរិក តែប៉ុណ្ណោះ។ ចំពោះករណីដែលកូនក្តីខ្លួន បានប្តឹងទៅក្រសួងមហាផ្ទៃពីការរំលោភភាគហ៊ុន ៥៤% ដោយហេតុថា ឈ្មោះ [redacted] ពីន មិនព្រមមកទទួលយកភាគលាភទៅតាមចំនួនភាគហ៊ុនរបស់ខ្លួន ហើយនឹងធ្វើការអះអាង ដោយផ្ទាល់មាត់ជាមួយគតិយជនផ្សេងគឺខ្លួនបានទិញយកភាគហ៊ុនរបស់អគ្គិសនី [redacted] ពីន ទាំងអស់រួចហើយ ទើបកូនក្តីខ្លួនមានការកើតទុក្ខមិនសុខចិត្ត ទើបឈានដល់ការដាក់ពាក្យបណ្តឹង។

៣-តាមសេចក្តីថ្លែងការរបស់មេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយថ្លែងការណ៍ថា៖ ខ្លួនដាក់ពាក្យបណ្តឹងតបនេះ គឺគោលបំណងរក្សាកិច្ចសន្យាទុកជាបានការដដែល។ ចំពោះការទាមទារចំណុចទី១ នៃពាក្យបណ្តឹងតប ដោយហេតុថា មុនដំបូងឡើយ កូនក្តីខ្លួនរកស៊ីជាមួយនិង [redacted] សុខន, [redacted] សឿន ក្នុងម្នាក់ៗមានភាគហ៊ុន ៣៣,៣៣ភាគរយ។ ក្រោយមកអ្នកទាំងបីនាក់ បានព្រមព្រៀងបញ្ចប់វិវាទគ្នា ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៨ ដោយបានសម្រេចប្រគល់អាជីវកម្មអគ្គិសនីព្រែកអំពិល ទៅឱ្យ [redacted] សឿន និង [redacted] ពីន, និងប្រគល់អគ្គិសនីពត់សរ និងបាក់ដាវ ទៅឱ្យ [redacted] សុខន ចំណែកអគ្គិសនី បឹងខ្យាង ត្រូវបានបញ្ចប់កិច្ចសន្យាជួលជាមួយលោកស្រី [redacted] សុជាតិ វិញ។ ចំពោះអគ្គិសនីព្រែកអំពិល ត្រូវបានបែងចែកភាគហ៊ុនជាថ្មី ដោយឈ្មោះ [redacted] ពីន ៣៣% ឈ្មោះ [redacted] សឿន ៥៤% និងឈ្មោះ [redacted] ណៅ ១៣% ដូចមានបញ្ជាក់ក្នុងកិច្ចសន្យាបែងចែកភាគហ៊ុន ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៨។ ក្រោយមកទៀត ឈ្មោះ [redacted] សឿន បានប្រាប់កូនក្តីខ្លួនមានបំណងចង់ទៅរស់នៅបរទេស វិញនិងមានបំណងមិនចង់រកស៊ីអគ្គិសនីតទៅទៀត ទើបគាត់លក់ភាគហ៊ុនគាត់ឱ្យកូនក្តីខ្លួនក្នុងតម្លៃ ៤៥៥០០០ (សែសិបប្រាំម៉ឺនប្រាំបួនពាន់) ដុល្លារអាមេរិក ដោយកូនក្តីខ្លួនបានកក់ប្រាក់ចំនួន ៥ម៉ឺនដុល្លារអាមេរិក នៅក្នុងថ្ងៃចុះកិច្ចសន្យាដោយមានបញ្ជាក់ក្នុងកិច្ចសន្យា ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៩។ ដោយសារតែក្នុងអំឡុងពេលនៃការប្រកបអាជីវកម្មជាមួយឈ្មោះ [redacted] សុខន ឆ្នាំ២០០៧ ឈ្មោះ [redacted] សឿន ដែលត្រូវជាបងប្រុសកូនក្តីខ្លួន តែងតែបានខ្ចីប្រាក់ជាហូរហែ ដើម្បីបង្កើតដើមទុន សរុបចំនួន ១២ម៉ឺនដុល្លារ ប៉ុន្តែមិនបានធ្វើជាលាយលក្ខណ៍អក្សរ។ ហេតុដូច្នេះហើយ ទើបឈ្មោះ [redacted] សឿន និងកូនក្តីខ្លួន បានព្រមព្រៀងគ្នាដោយមិនបានធ្វើជាលាយលក្ខណ៍អក្សរថា នៅថ្ងៃប្រគល់លុយបង្គ្រប់ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ អាចឱ្យកូនក្តីខ្លួនដកប្រាក់ចំនួន ១២ម៉ឺនដុល្លារអាមេរិក ចេញពីថ្ងៃទិញលក់បង្គ្រប់បាន។ លុះដល់ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ កូនក្តីខ្លួនបានជូនដំណឹងទៅលោក [redacted] សឿន ដើម្បីសុំអនុវត្តកាតព្វកិច្ចបង់ប្រាក់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ប៉ុន្តែឈ្មោះ [redacted] សឿន បានពន្យារពេលដោយលើកហេតុផលថា មេធាវីមិនអាចចូលរួមបាន និងវល់ ហេតុដូច្នេះ កូនក្តីខ្លួនបានជូនដំណឹងជាលាយលក្ខណ៍អក្សរដោយកំណត់ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៩ ម៉ោង ២រសៀល នៅការិយាល័យមេធាវី [redacted] ដោយមានបងប្អូនចូលរួមដឹងលឺ ផងដែរ។ នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៩ កូនក្តីខ្លួនបានទទួលលិខិតជូនដំណឹងពីលោកមេធាវី [redacted] ឱ្យអនុវត្តកិច្ចសន្យាប្រាក់កក់ខាងលើ ក្នុងថ្ងៃកំណត់ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។ បន្ទាប់ពីកូនក្តីខ្លួន ទទួលលិខិតជូនដំណឹងពីលោកមេធាវីរួច កូនក្តីខ្លួនមានចេតនាបន្តនូវការបង់ប្រាក់ ប៉ុន្តែនៅក្នុងលិខិតជូនដំណឹងនោះ មិនបានកំណត់ពេលវេលា និងទីកន្លែងឱ្យច្បាស់លាស់ ដើម្បីឱ្យកូនក្តីខ្លួនអនុវត្តកាតព្វកិច្ចបង់ប្រាក់ឡើយ។ទើបកូនក្តីខ្លួនជូនដំណឹងទៅឱ្យឈ្មោះ [redacted] សឿន វិញ ដោយស្នើសុំឱ្យគាត់មកទទួលប្រាក់បង្គ្រប់នៅទីស្នាក់ការអគ្គិសនី [redacted] ពីន ស្ថិតនៅភូមិព្រែកក្របៅ ទី៣ ឃុំព្រែកអំពិល ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល វេលាម៉ោង ៣រសៀល ដែលជាទីកន្លែងប្រកបអាជីវកម្មរួមគ្នា រវាងកូនក្តីខ្លួន និងឈ្មោះ [redacted] សឿន។ ផ្ទុយមកវិញ កូនក្តីខ្លួនបានទទួលលិខិតជូនដំណឹង ដាច់ប្រាក់

កក់ និងបញ្ចប់កិច្ចសន្យា ប្រាក់កក់ពីលោកមេធាវី [redacted] ទៅវិញ ទាំងដែលកូនក្តីខ្លួន ព្យាយាមអនុវត្តនូវកាតព្វកិច្ចបង់ប្រាក់ជាច្រើនលើកច្រើនសារដូចបានរៀបរាប់ខាងលើ ហើយឈ្មោះ [redacted] សឿន តែងតែគេចវេះមិនទទួលប្រាក់បង្គ្រប់ពីកូនក្តីខ្លួនផងនោះ។ តាមរយៈការរៀបរាប់ខាងលើនេះ បញ្ជាក់ឱ្យឃើញថា កូនក្តីខ្លួន មិនមានកំហុសក្នុងការអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យាកក់ប្រាក់ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៩ ឡើយ។ ហើយកូនក្តីខ្លួននៅតែមានបំណងទទួលទិញយកភាគហ៊ុន ចំនួន ៥៤% ពីឈ្មោះ [redacted] សឿន ដដែល។ ចំពោះការទាមទារចំណុចទី៣ ទី៤ នៅក្នុងពាក្យបណ្តឹងតប កូនក្តីខ្លួនរក្សាការទាមទារដូចមានក្នុងបណ្តឹងតប ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៩ និងសេចក្តីថ្លែងការណ៍ក្នុងឯកសារ ត្រៀម ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២០ របស់មេធាវី [redacted] និងមេធាវី [redacted]។

៤-មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទបានសុំច្រានចោលពាក្យបណ្តឹងតប ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៩ ដោយហេតុថា កាតព្វកិច្ចនៃការបង់ប្រាក់ ដូចបានលើកឡើងខាងលើ គឺផ្ទុយពីកិច្ចសន្យាកក់ប្រាក់ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៩។ ក្រោយពីមានការយឺតយ៉ាវ ក្នុងការបង់ប្រាក់បង្គ្រប់ កូនក្តីខ្លួនតាមរយៈការជូនដំណឹងរបស់មេធាវីឈ្មោះ [redacted] បញ្ញា ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ គឺបង់ប្រាក់ឱ្យកូនក្តីខ្លួនខ្វះ ដោយបង់តែចំនួន ២៨៩០០០ (ម្ភៃប្រាំបីម៉ឺនប្រាំបួនពាន់) ដុល្លារអាមេរិក ទើបកូនក្តីខ្លួន ធ្វើលិខិតជូនដំណឹងឱ្យអនុវត្តកិច្ចសន្យា ដោយបង់ប្រាក់បង្គ្រប់ តែដើមបណ្តឹងតប នៅតែមិនបង់ប្រាក់ឱ្យគ្រប់ចំនួនដដែល ទើបកូនក្តីខ្លួនជូនដំណឹងអំពីការដាច់ប្រាក់កក់ និងបន្តបន្ទាប់ ជូនដំណឹងអំពីការលុបកិច្ចសន្យាទិញលក់ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៩ យោងទៅលើការជូនដំណឹងនៅក្នុងនីតិវិធីនៃការជូនដំណឹង របស់កូនក្តីខ្លួនគឺធ្វើឡើងតាមទម្រង់ច្បាប់។ មកដល់បច្ចុប្បន្ននេះ កូនក្តីខ្លួននៅតែរក្សាតាមពាក្យបណ្តឹង ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៩ និងពាក្យសុំកែតម្រូវពាក្យបណ្តឹង ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ទុកជាបានការ ដោយហេតុថា នេះមិនមែនជាកំហុសរបស់កូនក្តីខ្លួន ក្នុងការមិនទទួលប្រាក់នោះទេ ដោយសារតែដើមបណ្តឹងតប មិនបំពេញកាតព្វកិច្ចឱ្យគ្រប់ចំនួនទឹកប្រាក់ដែលត្រូវបង់ គឺ ៤០៩០០០ (សែសិបម៉ឺនប្រាំបួនពាន់) ដុល្លារអាមេរិក។

៥-តាមសេចក្តីថ្លែងការណ៍តបរបស់មេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ៖ ចំពោះការអនុវត្តកាតព្វកិច្ច របស់កូនក្តីខ្លួន គឺមិនមានកំហុសទេ ដោយហេតុថា ទី១ នៅក្នុងទំនាក់ទំនងរវាងកូនក្តីខ្លួន និង សាន់ សឿន គឺជាបងប្អូនបង្កើតដែលជាទូទៅ គឺច្រើនតែការធ្វើកិច្ចសន្យា ឬធ្វើសកម្មភាពផ្សេងៗ គឺច្រើនតែធ្វើឡើងដោយផ្ទាល់មាត់។ ទី២ ក្នុងវិស័យជំនួញជួញដូរ ដែលច្រើនអនុវត្តទូទៅនៅប្រទេសកម្ពុជា នាពេលបច្ចុប្បន្ន គឺតែងតែទុកចិត្តគ្នា និងអនុវត្តការរកស៊ីតាមទំនៀមទំលាប់។ ទី៣ កន្លងមក នៅក្នុងការរកស៊ីរវាងកូនក្តីខ្លួន និងឈ្មោះ [redacted] សឿន គឺឈ្មោះ [redacted] សឿន តែងឱ្យកូនក្តីខ្លួន ធ្វើនេះធ្វើនោះ តាមរយៈផ្ទាល់មាត់ដែរ។ តាមរយៈការលើកឡើងទាំង០៣ ចំណុចនេះ គឺអាចបញ្ជាក់បានថាកូនក្តីខ្លួន និងឈ្មោះ [redacted] សឿន ពិតជាមានការព្រមព្រៀងដោយផ្ទាល់មាត់ ឱ្យកូនក្តីខ្លួនដកប្រាក់ដែលខ្លួនបានជំពាក់ចេញពីប្រាក់បង់ថ្លៃបង្គ្រប់ទាំងអស់ពិតប្រាកដមែន ទើបកូនក្តីខ្លួន នៅតែរក្សាគោលជំហរយ៉ាងម៉ឺងម៉ាត់បង់ប្រាក់បង្គ្រប់តែ ២៨៩០០០ (ម្ភៃប្រាំបីម៉ឺនប្រាំបួនពាន់) ដុល្លារអាមេរិក ចាត់តាំងពីមានវិវាទកើតឡើងរហូតដល់មានពាក្យបណ្តឹងនេះ។

៦-ចុងចម្លើយបានប្តឹងតប ដោយសុំឲ្យតុលាការបង្គាប់ឲ្យដើមចោទឈ្មោះ [redacted] សឿន ផ្ទេរភាគហ៊ុនចំនួន៥៤%នៅក្នុងសហគ្រាសអគ្គសនីសុខ ពីន 209L មកឲ្យចុងចម្លើយឈ្មោះ [redacted] ពីន តាមកិច្ចសន្យាកក់ប្រាក់ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៩ រវាងអ្នកលក់ឈ្មោះ [redacted] សឿន និងអ្នកទិញឈ្មោះ [redacted] ពីន ដោយសារតែភាគីអ្នកលក់ឈ្មោះ [redacted] សឿន គេចវេះ មិនព្រមមកទទួលប្រាក់ថ្លៃបង់បង្គ្រប់ថ្លៃទិញ-លក់ភាគហ៊ុន ដែលក្នុងមាត្រា៥៣០ នៃក្រមរដ្ឋប្បវេណីបានចែងថា អ្នកលក់មានការណីយកិច្ចត្រូវផ្ទេរសិទ្ធិលើទ្រព្យសម្បត្តិដែលខ្លួនបានលក់ទៅឲ្យអ្នកទិញ ដូច្នេះឈ្មោះ [redacted] សឿន ត្រូវមានកាតព្វកិច្ចផ្ទេរភាគហ៊ុនចំនួន៥៤%ដែលបានលក់ទៅឲ្យឈ្មោះ [redacted] ពីន ។ ប៉ុន្តែ ផ្អែកតាមការកំណត់យកថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ដែលជាថ្ងៃបង់ប្រាក់បង្គ្រប់ស្រប



Scanned with CamScanner

តាមកិច្ចសន្យាកក់ប្រាក់ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៩ លិខិតជូនដំណឹង ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៩ លិខិតជូនដំណឹងដាច់ប្រាក់កក់ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៩ និងលិខិតជូនដំណឹងពីការបញ្ចប់កិច្ចសន្យាកក់ប្រាក់ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៩ របស់មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទនោះ ឃើញថាចុងចម្លើយពុំបានអនុវត្តតាមខ្លឹមសារនៃកិច្ចសន្យា ខ្វះសុចរិតភាពក្នុងនាមជាអ្នកទិញ តាមមាត្រា ៥៥៥ កថាខណ្ឌទី១ "ករណីយកិច្ចបង់ ថ្លៃទិញ" នៃក្រមរដ្ឋប្បវេណី។

៧-តាមការអះអាងរបស់ភាគីដើមចោទ និងចុងចម្លើយ និងការពិនិត្យភស្តុតាងជាឯកសារ រួចមកឃើញថា ភាគីទាំងពីរពិតជាបានព្រមព្រៀងគ្នា ធ្វើសេវាកម្មអគ្គិសនីដែលដើមចោទមានភាគហ៊ុន៥៤ភាគរយ ចុងចម្លើយមាន៣៣ភាគរយ និងឈ្មោះ [redacted] ណាំ មាន១៣ភាគរយ ប្រាកដមែន។ ក្រោយមកដើមចោទ បានព្រមព្រៀងផ្ទេរភាគហ៊ុន ៥៤% នៃអគ្គិសនី ២០៥អ ក្នុងតម្លៃ ៤៥៥០០០ (សែសិបប្រាំម៉ឺនប្រាំបួនពាន់) ដុល្លារអាមេរិក ដោយកក់ប្រាក់ចំនួន ៥០០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក និងកំណត់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ដើម្បីបង់ប្រាក់បង្គ្រប់។ មកដល់កំណត់ចុងចម្លើយមិនបានយកលុយមកបង់ទេ ទោះបីជាមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទបានដាស់តឿនឲ្យ អនុវត្តកាតព្វកិច្ច តាមពេលកំណត់យកថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ដែលជាថ្ងៃបង់ប្រាក់បង្គ្រប់ស្របតាមកិច្ចសន្យាកក់ប្រាក់ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៩ លិខិតជូនដំណឹង ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៩ លិខិតជូនដំណឹងដាច់ប្រាក់កក់ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៩ និងលិខិតជូនដំណឹងពីការបញ្ចប់កិច្ចសន្យាកក់ប្រាក់ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៩ របស់មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទយ៉ាងណាក៏ដោយ ក៏ចុងចម្លើយមិនព្រមអនុវត្តតាមឡើយ ។ ផ្ទុយទៅវិញ ចុងចម្លើយបានអះអាងថា ដោយសារភាគីដើមចោទបានជំពាក់ប្រាក់១៧០.០០០(ដប់ប្រាំពីរម៉ឺន) ដុល្លារអាមេរិក និងគ្មានបំណងរកស៊ីអគ្គិសនីទៀត ដើមចោទក៏បានព្រមព្រៀងធ្វើការលក់ភាគហ៊ុនរបស់ខ្លួន ដោយនិយាយប្រាប់បងខ្លួន និងខ្លួនថាលុយ ១២០០០០ (ដប់ពីរម៉ឺន) ដុល្លារអាមេរិក នោះ ថា ពេលឱ្យលុយផ្តាច់ ចាំកាត់កងគ្នា និងប្រាក់ ១២០០០០ (ដប់ពីរម៉ឺន) ដុល្លារអាមេរិក នេះ ទុកស៊ីការប្រាក់ ។ ត្រង់ចំណុចនេះ តុលាការយល់ឃើញថា ការអះអាងរបស់ចុងចម្លើយពុំមានភស្តុតាងជាឯកសារណាមកបញ្ជាក់ ដើម្បីឲ្យតុលាការជឿបានឡើយ ក្រៅពីព័ត៌មានដែលទទួលបានពីសាក្សីឈ្មោះ [redacted] យឺន សាក្សីឈ្មោះ [redacted] ណាំ និងឈ្មោះ [redacted] ផាននី តែប៉ុណ្ណោះ។ ការមិនអនុវត្តកាតព្វកិច្ចរបស់ចុងចម្លើយឈ្មោះ [redacted] ពីន ជាការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ។ គប្បីតុលាការសម្រេចរំលាយកិច្ចសន្យាកិច្ចសន្យាកក់ប្រាក់ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៩ មាត្រា ៤០៨ និងមាត្រា៤១១ នៃក្រមរដ្ឋប្បវេណី។

៨-ដើមចោទបានទាមទារជម្ងឺចិត្តចំនួន ២០.០០០.០០០(ម្ភៃលាន )រៀលពីចុងចម្លើយ ដោយសារចុងចម្លើយមិនបានអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យាកក់ប្រាក់ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៩ ។ តុលាការនឹងធ្វើការពិចារណាលើការខូចខាតទៅតាមស្ថានភាពជាក់ស្តែង។

៩-ដើមចោទ បានប្តឹងសុំអនុវត្តជាបណ្តោះអាសន្នចំណុចទី១ និងចំណុចទី២ នៃពាក្យបណ្តឹង។ តុលាការយល់ឃើញថា ការស្នើសុំឱ្យអនុវត្តជាបណ្តោះអាសន្នលើចំណុចទី១ នៃពាក្យបណ្តឹងនេះ គឺមិនមានភាពចាំបាច់ នោះទេ ព្រោះចំណុចទី១ នៃពាក្យបណ្តឹង ការសុំរំលាយកិច្ចសន្យានេះ គឺជាចំណុចដែលដើមចោទ និងចុងចម្លើយ មានវិវាទគ្នា ហើយការសម្រេចសេចក្តីអាចនឹងមានការប្រែប្រួលនៅតុលាការជាន់ខ្ពស់ ដែលជាហេតុនាំឱ្យមានពិបាកក្នុងធ្វើបដិទានវិញ នាពេលអនាគត។ ហេតុដូច្នេះ គប្បីតុលាការសម្រេចច្រានចោល ការប្តឹងសុំឱ្យប្រកាសអនុវត្តជាបណ្តោះអាសន្ន តាមមាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

១០-ប្រាក់ប្រដាប់ក្តី តុលាការ នឹងពិចារណាសម្រេចតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។



Scanned with CamScanner

## សេចក្ដីសម្រេចបញ្ចប់

១-ទទួលពាក្យបណ្ដឹង ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] សឿន ជាដើមចោទ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

២-ទទួលស្គាល់ការប្រគល់សិទ្ធពីឈ្មោះ [redacted] សឿន ឱ្យលោកមេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិ ទុកជាត្រឹមត្រូវតាមច្បាប់។

៣-ទទួលស្គាល់ការប្រគល់សិទ្ធិពីឈ្មោះ [redacted] ពីន ឱ្យលោកមេធាវីឈ្មោះ [redacted] និងមេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិ ត្រឹមត្រូវតាមច្បាប់។

៤-ប្រានចោលការទាមទាររបស់ចុងចម្លើយឈ្មោះ [redacted] ពីន នៅក្នុងពាក្យបណ្ដឹងតប ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៩។

៥-រំលាយកិច្ចសន្យា លក់-ទិញ ភាគហ៊ុន ៥៤% ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៩ រវាងឈ្មោះ [redacted] សឿន និងឈ្មោះ [redacted] ពីន។

៦- ប្រគល់ភាគហ៊ុន ៥៤% ឱ្យទៅដើមចោទវិញ ចាប់ពីថ្ងៃសាលក្រមចូលជាស្ថាពរតទៅ។

៧- ប្រគល់ប្រាក់កក់ចំនួន ៥០០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក ឱ្យទៅចុងចម្លើយឈ្មោះ [redacted] ពីន វិញ នៅថ្ងៃសាលក្រមស្ថាពរ។

៨-បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] ពីន បង់ជម្ងឺចិត្ត និងការខូចខាត ដល់ដើមចោទឈ្មោះ [redacted] សឿន ចំនួន ២០ ០០០ ០០០ (ម្ភៃលាន) រៀល ។

៩-ប្រានចោលការទាមទាររបស់ដើមចោទ ចំណុចស្នើសុំសាលក្រមប្រកាសអនុវត្តបណ្ដោះអាសន្ន។

១០-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ ។

សាលក្រមនេះ ទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២០ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ ចំពោះមុខគូភាគី និងមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ និងចុងចម្លើយ ។

ទុកសិទ្ធិប្ដឹងឧទ្ធរណ៍ ក្នុងកំណត់ច្បាប់ ។

**ចៅក្រម**

**ហត្ថលេខា និង ត្រា:** [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ៥កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ធ្វើនៅខេត្តកណ្ដាល ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**

[redacted]